# របៀបដំឡើងយូនីកូដខ្មែរ

## ១ ដំឡើង កម្មវិធីយូនីកូដខ្មែរ

- សូមចុចទ្វេដងលើឯកសារ KhmerUnicode2.0.0.exe
- បន្ទាប់មកវានឹងបង្ហាញផ្ទាំងដូចខាងក្រោម រួចចុចប៊ូតុង Next




- ចុចប៊ូតុង Next




- ចុចប៊ូតុង OK




កុំព្យូទ័ររបស់អ្នកត្រូវការឯកសារមួយចំនួន ។
សូមចុចប៊ូតុង **OK**

- ចុចប៊ូតុង Browse




រួចចុចប៊ូតុង **Browse**

- ចុចប៊ូតុង Open




- ចុចប៊ូតុង OK




- សូមរង់ចាំ រហូតដល់វាបង្ហាញផ្ទាំងដូចខាងក្រោម រួចចុចប៊ូតុង Finish




**ចំណាំ ៖** ក្រោយពីដំឡើងយូនីកូដខ្មែរហើយសូមចាប់ផ្តើមកុំព្យូទ័រ របស់អ្នកឡើងវិញ ។

ខាងក្រោមនេះគឺជា រូបតំណាងប្តូរក្តារចុច នៅលើរបារភារកិច្ចរបស់ Windows ៖

| | |
|---|---|
|   | នេះជារូបតំណាងក្តារចុចភាសាអង់គ្លេស |
|   | នេះជារូបតំណាងក្តារចុចភាសាខ្មែរ |

| | |
|---|---|
|   | ដើម្បីប្តូរពីប្លង់ក្តារចុចមួយ ទៅក្តារចុចមួយទៀត អ្នកត្រូវចុចលើប៊ូតុង អក្សរកាត់ និង ជ្រើសយក ភាសាដែលអ្នកត្រូវការ ។<br><br>អ្នកក៏អាចប្តូរ ក្តារចុច ដោយសង្កត់គ្រាប់ចុច ជំនួស (Alt) ព្រមគ្នាជាមួយនឹង ប្តូរ (Shift) ។ |
|   | ចំពោះវីនដូវីស្តា រូបតំណាងក្តារចុចភាសាខ្មែរវាបង្ហាញជា ៖<br><br>KH Khmer (Cambodia) |

## ២ របៀបពិនិត្យមើលថាតើកុំព្យូទ័រដំណើរការដោយរលូនជាមួយយូនីកូដខ្មែរដែរឬទេ?

ក្រោយពីដំឡើងយូនីកូដខ្មែររួចរាល់ហើយអ្នកអាចពិនិត្យមើលកុំព្យូទ័ររបស់អ្នកថាតើវាដំណើរការដោយរលូនជាមួយនឹងយូនីកូដខ្មែរឬទេ នោះអ្នកអាចពិនិត្យបានដោយវិធីដូចខាងក្រោម ៖

- ចុចប៊ូតុង Start => Programs => Khmer Unicode 2.0 => Khmer Unicode Watcher

  កម្មវិធីនេះនឹងបង្ហាញថាតើកុំព្យូទ័ររបស់អ្នកដំណើរការដោយរលូនជាមួយនឹងយូនីកូដខ្មែរដោយអ្នកអាចសម្គាល់ដូចខាងក្រោម ៖




ក្នុងប្រអប់ System compartibility ៖

- ប្រសិនបើ មានធីកពណ៌បៃតងទាំង ៤ចំណុចនោះបានន័យថាកុំព្យូទ័ររបស់អ្នកវាដំណើរការដោយរលូនជាមួយយូនីកូដខ្មែរ ។
- ប្រសិនបើត្រង់ចំណុច Version of usp10.dll បង្ហាញសញ្ញាខ្វែងពណ៌ក្រហម នោះកុំព្យូទ័ររបស់អ្នកវានឹងមិន

ដំណើរការដោយរលូនជាមួយយូនីកូដខ្មែរទេ ។ អ្នកអាចចុចប៊ូតុង Copy to System ដើម្បីចម្លងឯកសារ usp10 ដែលត្រឹមត្រូវចូលក្នុងប្រព័ន្ធ ។ (ឯកសារ usp10 ដែលធ្វើឲ្យយូនីកូដខ្មែរដំណើរការដោយរលូនត្រូវមានកំណែចាប់ពី 1.0465....ឡើងទៅ) ។

- ប្រសិនបើត្រង់ចំណុច Khmer keyboard layout បង្ហាញសញ្ញាខ្វែងពណ៌ក្រហម នោះកុំព្យូទ័ររបស់អ្នកវានឹងមិនអាចវាយអត្ថបទជាមួយយូនីកូដខ្មែរបានទេ ។

  ដូច្នេះអ្នកត្រូវចុចប៊ូតុង Enable/Install ដំឡើង Khmer Unicode Keyboard ។